**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខ:..១១៨..............ប្រក.សក.ពទ

# ប្រកាស

# ស្តីពី

# ការបង្កើតគណៈកម្មការរៀបចំផែនការមេបច្ចេកវិទ្យាសម្រាប់ វិស័យសាធារណការ និងដឹកជញ្ជូន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដំឡើង នាយកដ្ឋានសំណង់ប្រព័ន្ធបម្រោះទឹកកខ្វក់ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធបម្រោះទឹកកខ្វក់ ស្ថិត ក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ ស្តីពីការប្រែក្លាយ និង ដំឡើងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូន ទៅជាវិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងប្រកាសលេខ ២៥១ សក.ប្រក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់នាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## **សម្រេច**

**ប្រការ ១.–**

ត្រូវបានបង្កើតគណៈកម្មការរៀបចំផែនការមេបច្ចេកវិទ្យាសម្រាប់វិស័យសាធារណការ និងដឹកជញ្ជូន ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ឈួន ទិន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ទ៉ាស៊ីម សុរិយា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **កែន រដ្ឋា** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៤. ឯកឧត្តម **សឿន ម៉ុនលី** | អគ្គនាយក នៃអគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ | សមាជិក |
| ៥. ឯកឧត្តម **ហោខ វត្តពិសិដ្ឋ** | អគ្គនាយក នៃអគ្គនាយកដ្ឋានសាធារណការ | សមាជិក |
| ៦. ឯកឧត្តម **ហ៊ាន ទុន្តា** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស | សមាជិក |
| ៧. ឯកឧត្តម **ឈួន ម៉ន់** | អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ៨. ឯកឧត្តម **ម៉ក់ ស៊ីដេត** | អគ្គនាយក នៃអគ្គនាយកដ្ឋានផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ | សមាជិក |
| ៩. ឯកឧត្តម **ឈៀង ពេជ្រ** | អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារកម្ម | សមាជិក |
| ១០. ឯកឧត្តម **សំរ៉េខឌី ណារ៉ូ** | អគ្គនាយក នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ | សមាជិក |
| ១១. ឯកឧត្តម **ហឿន សំនៀង** | នាយកវិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១២. ឯកឧត្តម **អ៊ុយ សុផល** | អគ្គាធិការ នៃអគ្គាធិការដ្ឋាន | សមាជិក |
| ១៣. លោក **ជា សុជាតិ** | នាយករងខុទ្ទកាល័យ | សមាជិក |
| ១៤. លោក **ហ៊ាន សុទ្ធាយុត្តិ** | ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ | សមាជិកអចិន្ត្រៃយ៍ |
| ១៥. លោក **អ៊ុក អ៊ួក** | ប្រធាននាយកដ្ឋានផ្លូវដែក | សមាជិក |
| ១៦. លោក **ចាន់ ដាឌុធ** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៧. លោក **លឹម សុខតៃ** | អគ្គនាយកមន្ទីរពិសោធន៍សំណង់ និងសាធារណការ | សមាជិក |
| ១៨. លោកស្រី **ហ៊ី ផានិន** | អគ្គនាយករង កំពង់ផែស្វយ័តភ្នំពេញ | សមាជិកា |
| ១៩. លោក **សោម ករណី** | នាយក នៃនាយកដ្ឋានព័ត៌មានវិទ្យា កំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិក |
| ២០. លោកស្រី **ម៉ុន សុគន្ធារ៉ា** | អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ | សមាជិកា |
| ២១. លោក **ឃុន សីហា** | មន្ត្រី នៃនាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ | សមាជិក |

**ប្រការ ២.-**

គណៈកម្មការរៀបចំផែនការមេបច្ចេកវិទ្យាសម្រាប់វិស័យសាធារណការ និងដឹកជញ្ជូន មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ និងសហការជាមួយក្រុមហ៊ុនដៃគូអភិវឌ្ឍន៍នានា ដើម្បីសិក្សា និងរៀបចំផែនការមេបច្ចេកវិទ្យាសម្រាប់វិស័យសាធារណការ និងដឹកជញ្ជូន ស្របតាមគោលនយោបាយឌីជីថលរបស់រាជរដ្ឋាភិបាល
- ប្រមូលធាតុចូលសំខាន់ៗ ក្នុងការរៀបចំផែនការមេបច្ចេកវិទ្យាសម្រាប់វិស័យសាធារណការ និងដឹកជញ្ជូន
- មានសិទ្ធិក្នុងការដឹកនាំប្រជុំជាមួយបណ្ដាតំណាងអង្គភាពគ្រប់គ្រងគម្រោង (PMU) នានា ដែលស្ថិតក្រោមក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីពិភាក្សាតម្រូវការនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាបម្រើដល់ការគ្រប់គ្រងគម្រោងឱ្យបានកាន់តែប្រសើរ
- ដោះស្រាយបញ្ហាប្រឈមនានា ក្នុងអំឡុងពេលសិក្សា និងអនុវត្តផែនការមេបច្ចេកវិទ្យា
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តគម្រោង អនុលោមតាមផែនការ និងពេលវេលាដែលត្រូវបានផ្ដល់សុពលភាពដោយ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
- ស្នើសុំគោលការណ៍អនុម័តពី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនលើឯកសារផែនការមេបច្ចេកវិទ្យាសម្រាប់វិស័យសាធារណការ និងដឹកជញ្ជូន ដើម្បីឈានទៅអនុវត្តនៅជំហានបន្ទាប់
- រៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តគម្រោងរៀបចំផែនការមេបច្ចេកវិទ្យា ដើម្បីអនុវត្ត
- រៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីគាំទ្រការអនុវត្តផែនការមេបច្ចេកវិទ្យា
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពការងារជាប្រចាំជូន រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
- ពិនិត្យពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកជំនួយហិរញ្ញវត្ថុដើម្បីអនុវត្តផែនការមេបច្ចេកវិទ្យាសម្រាប់វិស័យសាធារណការ និងដឹកជញ្ជូន
- ពិនិត្យ និងរៀបចំផែនការតភ្ជាប់ប្រព័ន្ធរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ជាមួយនឹងប្រព័ន្ធស្ថាប័នដទៃ
- រៀបចំកិច្ចប្រជុំរៀងរាល់មួយខែម្ដង ដើម្បីពិនិត្យវឌ្ឍនភាពការងារ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការណែនាំរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ ៣.-**

ត្រូវបានបង្កើតលេខាធិការដ្ឋាន នៃគណៈកម្មការរៀបចំផែនការមេបច្ចេកវិទ្យា សម្រាប់វិស័យសាធារណការ និងដឹកជញ្ជូន ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោកស្រី **ម៉ុន សុគន្ធារ៉ា** | អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ | ប្រធាន |
| ២. លោក **ណារ៉ា ទិព្វកល្យាណ** | អនុប្រធាននាយកដ្ឋាននីតិកម្ម | អនុប្រធាន |
| ៣. លោកស្រី **នួន សុគន្ធា** | អនុប្រធានការិយាល័យនៃនាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ | សមាជិកា |
| ៤. លោក **អ៊ាស៊ីម នីរិយ៉ាបុណ្ណ** | មន្ត្រី នៃនាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ៥. លោក **សេខ ពិសិដ្ឋ** | មន្ត្រី នៃនាយកដ្ឋាននីតិកម្ម | សមាជិក |

**ប្រការ ៤.-**

លេខាធិការដ្ឋាន នៃគណៈកម្មការរៀបចំផែនការមេបច្ចេកវិទ្យាសម្រាប់វិស័យសាធារណការ និងដឹកជញ្ជូន មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងការបែងចែកភារកិច្ចការងារជូនគណៈកម្មការពិនិត្យសម្រេច
- ជាសេនាធិការទទួលបន្ទុកផ្នែករដ្ឋបាល និងហិរញ្ញវត្ថុរបស់គណៈកម្មការ
- តាមដានការអនុវត្តផែនការសកម្មភាព នៃការអនុវត្តគម្រោងរៀបចំផែនការមេបច្ចេកវិទ្យា របស់ក្រុមការងារបច្ចេកទេស តាមគោលការណ៍របស់គណៈកម្មការ
- រៀបចំរបាយការណ៍ អំពីបញ្ហាប្រឈមពីរបៀបរបបធ្វើការងារ ដើម្បីស្នើសុំគោលការណ៍ដោះស្រាយឱ្យបានទាន់ពេលវេលា
- សម្របសម្រួលរៀបចំកិច្ចប្រជុំនានារបស់គណៈកម្មការ និងក្រុមការងារចំណុះ ជាមួយអង្គភាពក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូន និងភាគីពាក់ព័ន្ធតាមការស្នើសុំ
- ពិនិត្យអនុលោមភាពរាល់ឯកសារពាក់ព័ន្ធ ដែលក្រុមការងារចំណុះបានរៀបចំ មុននឹងដាក់ឆ្លងទៅប្រធានគណៈកម្មការ
- រៀបចំខ្លឹមសារព្រាងលិខិតផ្លូវការនានា ជូនគណៈកម្មការ ទៅគ្រប់អង្គភាពពាក់ព័ន្ធ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
- រៀបចំរបាយការណ៍អំពីវឌ្ឍនភាពការងារប្រចាំខែ និងតាមការចាំបាច់ជូនគណៈកម្មការ
- បំពេញការងារផ្សេងទៀតតាមការណែនាំរបស់គណៈកម្មការរៀបចំផែនការមេបច្ចេកវិទ្យាសម្រាប់វិស័យសាធារណការ និងដឹកជញ្ជូន។

**ប្រការ ៥.-**

អនុប្រធាន សមាជិក សមាជិកា នៃគណៈកម្មការនេះ ព្រមទាំងលេខាធិការដ្ឋានត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានគណៈកម្មការអាចកោះអញ្ជើញ និងដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិរបស់ប្រធាន។

គណៈកម្មការនេះ មានសិទ្ធិអញ្ជើញភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាចូលរួមប្រជុំតាមការចាំបាច់។

គណៈកម្មការនេះ មានសិទ្ធិស្នើសុំបង្កើតក្រុមការងារតាមការចាំបាច់។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត គ្រប់ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ និងប្រការ៣ ត្រូវទទួលបន្ទុកអនុវត្តខ្លឹមសារនៃប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ.ពុធ..១៣កើត.ខែ..អាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១.....ខែ.កក្កដា..ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន_ចាន់ថុល**

<u>**កន្លែងទទួល៖**</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- រដ្ឋបាលរាជធានី-ខេត្ត

  ***" ដើម្បីជូនជ្រាប "***
- ដូចប្រការ ៧

  ***" ដើម្បីអនុវត្ត "***
- ឯកសារ កាលប្បវត្តិ